សៀវភៅណែនាំសកម្មភាពនិស្សិតគ្រូគង្វាល

សំរាប់អោយគ្រូបង្ហាត់យកទៅប្រើជាមួយនិស្សិតម្នាក់ៗ



ផ្នែកណែនាំ និង ឧទាហរណ៍.....ទំព័រ ទី ៣

ផ្នែកសកម្មភាព.....ទំព័រ ទី ២៥

ផ្នែកតារាងសកម្មភាព.....ទំព័រ ទី ១២៩

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



ផ្នែកណែនាំ និង ឧទាហរណ៍

តារាងសកម្មភាព - កិរិត ទី ១ (ក្រុមជំនុំចាប់ផ្តើម)

ផ្នែកផ្សេងៗនៃកិច្ចការឃ្វាលរបស់គ្រូគង្វាល	សកម្មភាព លេខសកម្មភាព	កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល
ការអធិស្ឋាន និងការថ្វាយបង្គំប្រចាំថ្ងៃ	អធិស្ឋាន និង រៀបចំផែនការដោយជំនឿ ស-១	កូនសៀវភៅ ទី ២០, ២៤
	មានជ័យជំនះដោយសារការអធិស្ឋាន ស-២	កូនសៀវភៅ ទី ១៣, ២៥
ការចែកចាយដំណឹងល្អ និងការបង្កើនចំនួនក្រុមជំនុំបន្ត	ទៅលេងសួរសុខទុក្ខ និង ចែកចាយដំណឹងល្អ ស-៣	កូនសៀវភៅ ទី ២, ១៥, ១៦, ១៧
	ធ្វើពិធីជ្រមុជទឹក និង ទទួលអ្នកជឿថ្មី ស-៤	កូនសៀវភៅ ទី ១
	អធិស្ឋានសំរាប់អ្នកជំងឺ និង មនុស្សដែលនៅក្រោមអំណាចអារក្ស ស-៥	កូនសៀវភៅ ទី ២៥
	ណែនាំប្រមូលសមាជិកទាំងអស់អោយចូលរួមក្នុងការផ្សព្វផ្សាយដំណឹងល្អ ស-៦	កូនសៀវភៅ ទី ៤, ៥, ៨, ២៦, ៣២
ការបង្រៀន និងការបង្កើតសាវ័ក	បង្រៀនអោយចេះរស់នៅតាមជីវិតគ្រីស្តជន ស-៧	កូនសៀវភៅ ទី ៧, ៣០, ៣៣
	បណ្តុះឱ្យមានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងមនុស្សឯទៀត .. ស-៨	កូនសៀវភៅ ទី ១៩, ២១
	បង្រៀនអោយចេះអាន និង ប្រតិបត្តិតាមព្រះគម្ពីរ ស-៩	កូនសៀវភៅ ទី ៩, ១៤

ការរៀបចំ ការដឹកនាំ និងអំណោយទានខាងព្រលឹងវិញ្ញាណ	រៀបចំក្រុមជំនុំ និង ការដឹកនាំក្នុងក្រុមជំនុំ ស-១២	កូនសៀវភៅ ទី ៣, ២៣
ការថ្វាយបង្គំ និង ការធ្វើពិធីកាច់នំប៉័ង រួមជាមួយអ្នកជឿឯទៀត	ជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់ ..... ស-១០ ថ្វាយបង្គំក្នុងក្រុមគ្រួសារ ស-១១	កូនសៀវភៅ ទី ១១, ១២, ១៣, ១៨, ៣១, ៣៤ កូនសៀវភៅ ទី ៦
ការថ្វាយដង្វាយនិង ការបំរើអ្នកខ្វះខាត	បង្កើតអោយមានការចាត់ចែងថវិកា/ការថ្វាយដង្វាយក្នុងក្រុមជំនុំ ស-១៥	កូនសៀវភៅ ទី ៣
ការប្រកបគ្នាក្នុងក្រុមជំនុំ និង ជីវិតក្រុមជំនុំ	បង្កើតអោយមានការប្រកបគ្នាក្នុងក្រុមជំនុំ ស-១៣	កូនសៀវភៅ ទី ២១
កិច្ចការឃ្វាលទំនាក់ទំនង និង ការប្រដៅទូន្មាន	សួរសុខទុក្ខ និង លើកទឹកចិត្តសមាជិក..... ស-១៤	កូនសៀវភៅ ទី ២២, ២៩
ការបង្ហាត់បង្រៀនគ្រូគង្វាល	ជ្រើសរើសនិស្សិតគ្រូគង្វាលថ្មី ... ស-១៦	កូនសៀវភៅ ទី ២៤, ១-៣៤, «សៀវភៅសំរាប់ណែនាំគ្រូបង្ហាត់និស្សិតគ្រូគង្វាល »
ការបង្កើតសាវ័កនៅក្នុងជាតិសាសន៍នានា	អធិស្ឋានសំរាប់ការផ្សព្វផ្សាយដំណឹងល្អក្នុងពិភពលោក ស-១៧	កូនសៀវភៅ ទី ២៧
ការវាយតម្លៃសកម្មភាពទាំងឡាយ	ពិនិត្យមើលសាឡើងវិញ និង វាយតម្លៃសកម្មភាពកិរិត ទី ១..... ស-១៨	កូនសៀវភៅ ទី ១០, ២៨

តារាងសកម្មភាព - កិរិត ទី ២ (ក្រុមជំនុំរីកចំរើនឡើង)

ផ្នែកផ្សេងៗនៃកិច្ចការឃ្វាលរបស់គ្រូគង្វាល	សកម្មភាព លេខសកម្មភាព	កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល
ការអធិស្ឋាន និងការថ្វាយបង្គំប្រចាំថ្ងៃ	រៀបចំអោយមានការអធិស្ឋានក្នុងក្រុមជំនុំ..... ស-១៩	កូនសៀវភៅ ទី ៤៧, ៥៧
ការចែកចាយដំណឹងល្អ និងការបង្កើនចំនួនក្រុមជំនុំបន្ត	ផ្សព្វផ្សាយដំណឹងល្អទៅទីកន្លែងថ្មីៗទៀត ស-២០	កូនសៀវភៅ ទី ៥២
	បង្កើតក្រុមជំនុំថ្មីៗទៀត ស-២១	កូនសៀវភៅ ទី ៣៧, ៥០, «សៀវភៅសំរាប់ណែនាំគ្រូបង្ហាត់និស្សិតគ្រូគង្វាល »
ការបង្រៀន និងការបង្កើតសាវ័ក	ចេញទៅបង្កើតសាវ័ក..... ស-២២	កូនសៀវភៅ ទី ៧
	ធ្វើអោយការបង្រៀនព្រះគម្ពីររីកចំរើនឡើង ស-២៣	កូនសៀវភៅ ទី ៤២, ៥១, ៦១
	រកផ្លូវដោះស្រាយកិច្ចការដែលទាក់ទងនឹងសេចក្តីបង្រៀនក្លែងក្លាយ .. ស-២៤	កូនសៀវភៅ ទី ៦២
	ប្រឈមមុខនឹងការប្រឆាំងជំទាស់ និងការបៀតបៀន ស-២៥	
ការរៀបចំ ការដឹកនាំ និងអំណោយទានខាងព្រលឹងវិញ្ញាណ	រៀបចំផែនការ និង ប្រគល់ភារៈកិច្ចអោយពួកអ្នកដឹកនាំ (អ្នកចាស់ទុំ)ធ្វើ ស-២៨	កូនសៀវភៅ ទី ៤៩
	រៀបចំផែនការ ដោយធ្វើប្រតិទិន និងគំរោងការងារប្រចាំថ្ងៃ ស-២៩	កូនសៀវភៅ ទី ៥៤
	ធ្វើការប្រជុំខាងផ្នែកគ្រប់គ្រងសំរាប់អ្នកដឹកនាំ ស-៣០	កូនសៀវភៅ ទី ៤៥

	ជួយឱ្យអំណោយទានរបស់ពួកអ្នកជឿ បានរីកចំរើនឡើង ស-៤៣	កូនសៀវភៅ ទី ៦០
	បង្កើតក្រុមសំរាប់ធ្វើការកសាង និង ធ្វើកិច្ចការបំរើ..... ស-៤៤	កូនសៀវភៅ ទី ៤៤
	រៀបចំបង្កើតអោយមានកិច្ចការបំរើ ពិសេសៗ ស-៤៥	កូនសៀវភៅ ទី ៤៤
	បង្កើតកិច្ចការបំរើសំរាប់កុមារ ... ស-៤៦	កូនសៀវភៅ ទី ៥១
	ណែនាំប្រមូលយុវជន..... ស-៤៧	
ការថ្វាយបង្គំ និង ពិធីកាច់នំបុ័ងរួម ជាមួយអ្នកជឿ ឯទៀត	អធិប្បាយសេចក្តីបង្រៀនរបស់ ព្រះគម្ពីរ ស-២៦	កូនសៀវភៅ ទី ៣៥, ៤៣, ៥៨, ៥៩
	រៀបចំអោយមានកម្មវិធីថ្វាយបង្គំ និង ការប្រជុំពិសេសៗ ស-២៧	កូនសៀវភៅ ទី ១២, ៣១, ៣៤
ការថ្វាយដង្វាយ និងការបំរើមនុស្ស ដែលខ្វះខាត	ណែនាំប្រមូលបងប្អូនក្នុងព្រះគ្រីស្ត អោយចេះទៅសួរសុខទុក្ខ ស-៤០	កូនសៀវភៅ ទី ៤៨
	ជួយមនុស្សដែលខ្វះខាត ស-៤១	កូនសៀវភៅ ទី ៤០
	ផ្គត់ផ្គង់គ្រួគង្វាល និង អ្នកធ្វើកិច្ចការ ផ្សេងៗទៀត ស-៤២	
	បំពេញតួនាទីជាប្រជាពលរដ្ឋ ... ស-៤៨	កូនសៀវភៅ ទី ៣៦
ការប្រកបគ្នាក្នុង ក្រុមជំនុំ និង ជីវិតក្រុមជំនុំ	រៀបចំសកម្មភាពសំរាប់ កំសាន្ត ស-៣១	កូនសៀវភៅ ទី ៤៦
	ដោះស្រាយជំលោះ និង ការបាក់ បែក..... ស-៣២	

កិច្ចការឃ្វាលទំនាក់ទំនង និងការប្រដៅទូន្មាន	ពង្រឹងជីវិតគ្រួសារ..... ស-៣៣	ក្លូនសៀវភៅ ទី ៥៦
	កសាងសេចក្តីស្រឡាញ់ ក្នុងក្រុមជំនុំ ស-៣៤	ក្លូនសៀវភៅ ទី ៥៣
	ប្រៀនប្រដៅដោយសេចក្តីស្រឡាញ់តាមរយៈព្រះគម្ពីរ ស-៣៥	ក្លូនសៀវភៅ ទី ៤១
	ដោះស្រាយបញ្ហា ដោយការប្រដៅទូន្មាន ស-៣៦	ក្លូនសៀវភៅ ទី ៣៩
	បង្ហាត់បង្រៀនអ្នកផ្តល់យោបល់ ចាប់ពីកិរិតដំបូងទៅ ស-៣៧	ក្លូនសៀវភៅ ទី ៣៩
	លើកទឹកចិត្ត និង អធិស្ឋានអោយអ្នកជំងឺ ស-៣៨	ក្លូនសៀវភៅ ទី ២៥, ៣៨
	រំដោះមនុស្ស ដែលនៅក្រោមអំណាចអារក្ស ស-៣៩	ក្លូនសៀវភៅ ទី ៥៧
ការបង្ហាត់បង្រៀនគ្រូគង្វាល	បង្ហាត់បង្រៀននិស្សិតគ្រូគង្វាលថ្មី ស-៤៩	ក្លូនសៀវភៅ ទី ២៤, «សៀវភៅណែនាំសំរាប់គ្រូបង្ហាត់និស្សិតគ្រូគង្វាល »
ការបង្កើតសាវ័កនៅក្នុងជាតិសាសន៍នានា	ណែនាំប្រមូលពួកសមាជិក ឱ្យចូលរួមក្នុងបេសកកម្មសកលលោក ស-៥០	ក្លូនសៀវភៅ ទី ២៧, ៣៧
	ចាប់ផ្តើមបង្ហាត់បង្រៀនសមាជិកអោយក្លាយជាគ្រីស្តទូត..... ស-៥១	ក្លូនសៀវភៅ ទី ៥៥, «សៀវភៅណែនាំសំរាប់បង្ហាត់បង្រៀនគ្រីស្តទូត »
	ផ្គត់ផ្គង់កិច្ចការគ្រីស្តទូត..... ស-៥២	
ការវាយតំលៃសកម្មភាព	ពិនិត្យសាឡើងវិញ និង វាយតម្លៃសកម្មភាពកិរិត ទី ២ ..... ស-៥៣	ក្លូនសៀវភៅ ទី ១០

តារាងសកម្មភាព - កិរិត ទី ៣ (ក្រុមជំនុំកើនចំនួនបន្ត)

ផ្នែកផ្សេងៗនៃកិច្ចការឃ្វាលរបស់គ្រូគង្វាល	សកម្មភាព លេខសកម្មភាព	កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល
ការអធិស្ឋាន និងការថ្វាយបង្គំប្រចាំថ្ងៃ	ជំរុញអោយក្រុមជំនុំទាំងអស់ អធិស្ឋានរួមគ្នា..... ស-៥៤	
ការចែកចាយដំណឹងល្អ និងការបង្កើនចំនួនក្រុមជំនុំបន្ត	ផ្សព្វផ្សាយដំណឹងល្អទៅតំបន់ផ្សេងៗទៀត និង ទៅប្រជាជនដែលមានជាតិសាសន៍ និង វប្បធម៌ផ្សេងៗទៀត ស-៥៥	កូនសៀវភៅ ទី ៣៧, ៥៥
	ចាត់ចែងការបង្កើនចំនួនបន្តនៃក្រុមជំនុំថ្មី..... ស-៥៦	
	បន្តបង្កើនចំនួនក្រុមថ្មីៗទៀត... ស-៥៧	កូនសៀវភៅ ទី ៣៧
ការបង្រៀន និងការបង្កើតសាវ័ក	ពង្រឹងការសិក្សា និង ការអនុវត្តតាមព្រះគម្ពីរ ស-៥៨	
	រៀបចំបង្កើតវិធីសាស្ត្របង្រៀនថ្មីៗទៀត ស-៥៩	
ការរៀបចំ ការដឹកនាំ និងអំណោយទានខាងព្រលឹងវិញ្ញាណ	រៀបចំបង្កើត និងពង្រីកបណ្តាញការងារ ដើម្បីជួយគ្នា និង ត្រួតពិនិត្យគ្នាទៅវិញទៅមក ស-៦៣	
	ធ្វើការវាយតំលៃ រៀបចំឡើងវិញ និងពង្រីកកិច្ចការបំរើ ស-៦៧	

ការថ្វាយបង្គំ និង ធ្វើពិធីកាច់នំប៉័ង រួមជាមួយអ្នកជឿ ឯទៀត	រៀបចំកម្មវិធីថ្វាយបង្គំរួមជាមួយ ក្រុមជំនុំច្រើន..... ស-៦០ ពង្រឹងកិច្ចការបំរើខាងតន្ត្រី និង ការច្រៀងសរសើរ ..... ស-៦១ បង្រៀនអ្នកអធិប្បាយ ឱ្យចេះអធិប្បាយ ប្រកបដោយប្រសិទ្ធិភាពកាន់តែខ្លាំង ឡើង ស-៦២	
ការថ្វាយដង្វាយ និងការបំរើមនុស្ស ដែលខ្វះខាត	ពង្រីកកិច្ចការបំរើខាង សង្គមកិច្ច..... ស-៦៨	
ការប្រកបគ្នាក្នុង ក្រុមជំនុំ និង ជីវិតក្រុមជំនុំ	ធ្វើអោយមានការប្រកបគ្នារវាង ក្រុមជំនុំទាំងអស់..... ស-៦៤ បណ្តុះបណ្តាលអោយមានការប្រកបគ្នា និង តយុទ្ធប្រឆាំងនឹងក្រិត្យវិន័យ និយម ស-៦៥	ក្លូនសៀវភៅ ទី ៦៣
កិច្ចការឃ្វាល ទំនាក់ទំនង និង ការប្រដៅទូន្មាន	ធ្វើអោយកិច្ចការបំរើខាងប្រដៅទូន្មាន រីកចំរើនបន្តទៅទៀត ស-៦៦	
ការបង្ហាត់បង្រៀន គ្រូគង្វាល	បង្កើត «បណ្តាញ »បង្ហាត់បង្រៀន គ្រូគង្វាលថ្មីៗទៀត..... ស-៦៩ ពង្រឹងគ្រូគង្វាល និង អ្នកចាស់ទុំទាំង អស់របស់ក្រុមជំនុំ..... ស-៧០ រៀបចំធ្វើក្លូនសៀវភៅថ្មីៗទៀតអំពី ការបង្ហាត់បង្រៀនគ្រូគង្វាល ... ស-៧១ ផ្តល់ការបង្ហាត់បង្រៀនកិរិតខ្ពស់ដល់ គ្រូគង្វាល ស-៧២	

ការបង្កើតសាវ័ក នៅក្នុងជាតិសាសន៍ នានា	ជ្រើសរើសបង្ហាត់បង្រៀន និងចាត់ គ្រីស្តទូតអោយចេញទៅបំពេញ កិច្ចការ ..... ស-៧៣ ត្រួតពិនិត្យ និង ផ្គត់ផ្គង់កម្មវិធីរបស់ គ្រីស្តទូត ស-៧៤	កូនសៀវភៅ ទី ២៧, ៣៧, ៥៥
ការវាយតម្លៃ សកម្មភាព	ពិនិត្យសាឡើងវិញ និង វាយតម្លៃ សកម្មភាពកិរិត ទី ៣..... ស-៧៥	កូនសៀវភៅ ទី ១0

ដើម្បីអាចយល់ពីតារាងសកម្មភាព

“សៀវភៅណែនាំសកម្មភាពនិស្សិតគ្រូគង្វាល”នេះ ជាមូលដ្ឋានរបស់កម្មវិធី “បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត” ។ ដូចនេះហើយ ទើបការរៀនអោយចេះប្រើសៀវភៅនេះ ជាការសំខាន់ ។

សូមមើលបញ្ជីសកម្មភាពទាំងមូល ដែលមានដាក់ជូននៅទំព័រ ទី ៤-១១ ។
សូមកត់សំគាល់ចន្លោះទាំងបី ។

- ចន្លោះទីមួយរៀបរាប់ពីផ្នែកផ្សេងៗនៃ “កិច្ចការឃ្វាលរបស់គ្រូគង្វាល” ។
- ចន្លោះទីពីររៀបរាប់ពី “សកម្មភាព” អមដោយលេខរៀងរបស់សកម្មភាពទាំងនោះ ។
- ចន្លោះទីបីរៀបរាប់ពី “កូនសៀវភៅសំរាប់សិក្សា” អមដោយលេខរៀងរបស់កូនសៀវភៅទាំងនោះ ។

អ្នកត្រូវប្រើបញ្ជីសកម្មភាពនេះ ដើម្បីជួយនិស្សិតគ្រូគង្វាលជ្រើសរើសសកម្មភាពទាំងឡាយដែលក្រុមជំនុំ ឬក្រុមរបស់គេត្រូវធ្វើ ។ កិច្ចការនេះនឹងមានពន្យល់នៅទំព័របន្តបន្ទាប់នេះ ។



សកម្មភាពទាំងនេះ ជាកូនសោសំរាប់អ្វីៗគ្រប់យ៉ាង ។ អ្នកអាចស្គាល់ថាជាសកម្មភាពណាមួយដោយសារតួអក្សរ « ស » និង លេខរៀង (ឧទាហរណ៍ : សកម្មភាព ស-១, សកម្មភាព ស-២, និង សកម្មភាព ស-៣...) ។

សកម្មភាពទាំងនេះ ត្រូវគេប្រមូលផ្តុំជា**ផ្នែកផ្សេងៗនៃកិច្ចការឃ្វាលរបស់គ្រូគង្វាល** ។ កិច្ចការឃ្វាលទូទៅទាំងនេះ នឹងមាននៅក្នុងកិរិតទាំងបីនៃការសិក្សា ។

កិច្ចការដែលត្រូវធ្វើ នៅពេលជួបជាមួយ
និស្សិតគ្រូគង្វាល ក្នុងវគ្គសិក្សាទីមួយ

១- ជ្រើសរើសនិស្សិតគ្រូគង្វាលថ្មី

ការសិក្សាក្នុងកម្មវិធីនេះ សំរាប់តែពួកអ្នកដឹកនាំកិច្ចការឃ្វាល ដែលព្រះគម្ពីរចាត់ទុកជាពួក «អ្នកដឹកនាំ»ប៉ុណ្ណោះ ។ បើសិនជាអ្នកទទួលមនុស្សផ្សេងទៀត ជានិស្សិតគ្រូគង្វាល នោះ «កម្មវិធីបង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត»™ នឹងបាត់បង់ភាពជាខ្នាតគំរូនៃកិរិតកិច្ចការឃ្វាល របស់កម្មវិធីនេះ ។

បំពេញ «**លិខិតចុះពត៌មានរបស់និស្សិត**» ដែលមានដាក់ជូននៅទំព័រ ទី ២៤ សំរាប់អោយអ្នកធ្វើបញ្ជីកត់ឈ្មោះ ។

២- ស្តាប់រចាយការណ៍របស់និស្សិតម្នាក់ៗ

អោយនិស្សិតធ្វើរបាយការណ៍អំពីការរីកចំរើន និងដំណើរការរបស់ក្រុមជំនុំ ឬ ក្រុមរបស់គេ ។ និស្សិតម្នាក់ៗត្រូវមានមុខងារឃ្វាលមួយ ។ បើសិនជានិស្សិតមិនទាន់មានមុខងារឃ្វាល គេក៏ត្រូវចាប់ផ្តើមពេលនោះភ្លាម ដោយផ្សាយដំណឹងល្អ និងបង្កើតសាវ័ក រហូតដល់បានប្រមូលគ្រួសារ និង មិត្តភ័ក្តិគេជាក្រុមមួយ ។

ណែនាំនិស្សិតអោយនិយាយអំពីកិច្ចការឃ្វាល ដែលគេចង់អនុវត្ត ដើម្បីធ្វើអោយមុខងារបំរើរបស់គេរីកចំរើនបាន ។

៣- រៀបចំគំរោងភារៈកិច្ចដែលត្រូវអនុវត្ត

ជួយនិស្សិតរៀបចំគំរោងកិច្ចការដែលនិស្សិត និងក្រុមគេត្រូវធ្វើ ។

ក- ប្រើ «តារាងសកម្មភាព»នៅទំព័រដំបូងបង្អស់របស់សៀវភៅណែនាំនេះ ដើម្បីជ្រើសយកសកម្មភាពណាមួយ ដែលនិស្សិតត្រូវយកទៅអនុវត្តជាមួយក្រុមរបស់គេ ស្របទៅតាមសេចក្តីត្រូវការបច្ចុប្បន្នរបស់ក្រុម និង មុខងារបំរើដែលក្រុមសុខចិត្តធ្វើ នៅពេលខាងមុខ ។

ខ- បើកទំព័រដែលមានសរសេរពីសកម្មភាព ដែលនិស្សិតគ្រូគង្វាលបានជ្រើសយក ដើម្បីពិនិត្យមើលពីកិច្ចការ ដែលត្រូវអនុវត្ត និង ការសិក្សាដែលទាក់ទងនឹងសកម្មភាព ។

ឧទាហរណ៍ : ឧបមាថា និស្សិតរបស់អ្នកជ្រើសយកសកម្មភាព ស-៣ ដែលនៅទំព័រ ទី ២៩ របស់សៀវភៅណែនាំនេះ ។

នៅពីក្រោមសកម្មភាព ស-៣ ដែលមានឈ្មោះថា "ទៅលេងសួរសុខទុក្ខ និង ចែកចាយដំណឹងល្អ" អ្នកនឹងឃើញ :

- ទាំង "កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)"
- ទាំង "ការសិក្សា (សំរាប់ជ្រើសរើស)"

ដែលនិស្សិតអាចជ្រើសរើសយកទៅអនុវត្ត ក្នុងការងារឃ្វាលដែលគេកំពុងធ្វើ ។

សូមកត់សំគាល់ថា "ការសិក្សា" ដែលជាផ្នែកមួយរបស់សកម្មភាព "ស-៣" ដាក់ជូនការសិក្សាបីប្រភេទសំរាប់ជ្រើសរើស :

- "ការអានព្រះគម្ពីរ"
- "កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល"
- "ការអានបន្ថែម" (សៀវភៅផ្សេងៗទៀតសំរាប់សិក្សា) ។



គ- ណែនាំនិស្សិតគ្រូគង្វាលអោយរៀបចំផែនការសំរាប់ការងាររបស់គេ និង ការងាររបស់ក្រុមគេ ស្របទៅតាម «កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស) » ។ និស្សិតត្រូវជ្រើសយកតែកិច្ចការសំរាប់ជ្រើសរើស ដែលទាក់ទងនឹងការងារ និង គោលដៅពិសេសរបស់គេប៉ុណ្ណោះ » ។

សូមអោយនិស្សិតសរសេរផែនការរបស់គេ ។ កំណត់ទាំងនេះនឹងរំលឹកគេ នៅពេលឆ្លងពីវគ្គសិក្សាមួយ ទៅវគ្គសិក្សាមួយទៀត ។ អ្នកដែលជាគ្រូបង្ហាត់ ក៏ត្រូវសរសេរផែនការរបស់និស្សិត ទុកក្នុងសៀវភៅកំណត់ដែរ ដើម្បីមើលឡើងវិញ នៅក្នុងវគ្គសិក្សាបន្ទាប់ ។



គ្រូសរសេរនៅក្នុងសៀវភៅកំណត់របស់គាត់ថា : សុភាពសរសេរនៅក្នុងសៀវភៅរបស់ខ្លួនថា :

អ្នកសិក្សា : ចាន់ សុភាព	ពេលប្រជុំ : ២/៦/២០០២
ពេលប្រជុំ : ២/៦/២០០២	កិច្ចការ : ទៅសួរសុខទុក្ខលោកតារា និងក្រុមគ្រួសាររបស់គាត់ ហើយចែកចាយដំណឹងល្អប្រាប់គេ ។
កិច្ចការ : ទៅសួរសុខទុក្ខលោកតារា និងក្រុមគ្រួសាររបស់គាត់ ហើយចែកចាយដំណឹងល្អប្រាប់គេ ។	ការសិក្សា : ម៉ាថាយ ២៨ និង កូនសៀវភៅ ទី ២ «របៀបផ្សព្វផ្សាយដំណឹងល្អ »
ការសិក្សា : ម៉ាថាយ ២៨ និង កូនសៀវភៅ ទី ២ «របៀបផ្សព្វផ្សាយដំណឹងល្អ »	ពេលប្រជុំលើកក្រោយ : ១៦/៦/២០០២
ពេលប្រជុំលើកក្រោយ : ១៦/៦/២០០២	

សំខាន់ណាស់ ដែលត្រូវអោយផែនការទាំងនោះច្បាស់លាស់ និង ជាក់លាក់ ។ សូមកត់សំគាល់ថា និស្សិតមិនគ្រាន់តែសរសេរថា «ផ្សាយដំណឹងល្អ»ប៉ុណ្ណោះទេ តែត្រូវសរសេរ ថា «លោកជុន និង គ្រួសារគាត់» ថែមទៀតគឺថា ឈ្មោះគ្រួសារ និង មនុស្សដែលគេត្រូវទៅផ្សាយដំណឹងល្អផង ។

៤- រៀបចំគំរោងសិក្សា

បន្ទាប់ពីផ្នែក «កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)» ដែលមានដាក់ជូននៅក្នុងសកម្មភាព អ្នកនឹងឃើញ «ការសិក្សា (សំរាប់ជ្រើសរើស)» ។ សូមជ្រើសរើស**បទព្រះគម្ពីរ**មួយ ឬ លើសមួយពីក្នុងបញ្ជី «ការអានព្រះគម្ពីរ» និង ជ្រើសរើស**កូនសៀវភៅ**មួយក្បាល ឬ លើសពីមួយក្បាលពីក្នុងបញ្ជី «កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល» ។

សូមកត់សំគាល់ថា **កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល**និមួយៗ មានលេខរៀងមួយ ។ កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត»™ ផ្តល់ជូនកូនសៀវភៅចំនួន ៦៣ ក្បាល ។ បើសិនជាអ្នករៀបចំទុកដាក់កូនសៀវភៅទាំងនោះតាមលេខរៀង អ្នកនឹងស្រួលរកកូនសៀវភៅដែលត្រូវការ ។ បើអ្នកលក់កូនសៀវភៅណាមួយអោយនិស្សិតរបស់អ្នក អ្នកត្រូវទិញយកមកបន្ថែមយ៉ាងឆាប់បំផុត ដើម្បីអោយអ្នកមានកូនសៀវភៅនៅគ្រប់លេខជានិច្ច ។

សូមកត់បន្ថែមគំរោងការសិក្សាទាំងនេះ ក្នុងកំណត់របស់អ្នក សំរាប់មើលឡើងវិញនៅក្នុងវគ្គសិក្សាបន្ទាប់ ។

៥- អធិស្ឋាន

សូមអធិស្ឋានសំរាប់និស្សិត និងសមាជិករបស់គេ ព្រមទាំងសំរាប់ផែនការរបស់គេ នៅពេលណាក៏បាន ក្នុងរយៈពេលសិក្សាជាមួយគ្នា ក្នុងវគ្គសិក្សា ។

កិច្ចការដែលត្រូវធ្វើក្រោយវគ្គសិក្សា

ធ្វើជាគំរូអោយនិស្សិតអាចធ្វើតាម



កិច្ចការដែលត្រូវធ្វើជាមួយនិស្សិតនៅក្នុងវគ្គសិក្សា ក្រោយៗទៀត

មុននឹងចាប់ផ្តើមវគ្គសិក្សានិមួយៗ អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ជួយ និង ដឹកនាំ ។

ស្តាប់

- ស្តាប់របាយការណ៍របស់និស្សិតអំពីកិច្ចការដែលនិស្សិត និង ក្រុមរបស់គេកំពុងធ្វើ ។
- ប្រៀបធៀបរបាយការណ៍នោះជាមួយកំណត់ត្រារបស់អ្នក ដែលអ្នកកត់ទុកនៅក្នុងវគ្គសិក្សាមុន ។
- ជួយនិស្សិតអោយអាចវាយតម្លៃការរីកចំរើនរបស់ក្រុមគេ ។

រៀបចំគំរោងធ្វើកិច្ចការថ្មីៗ ដែលត្រូវអនុវត្ត

ជួយនិស្សិតរៀបចំផែនការ ដោយសួរសំណួរដូចខាងក្រោមនេះ :

- តើសមាជិករបស់អ្នកកំពុងធ្វើកិច្ចការ ដែលបានរៀបចំនៅពេលប្រជុំមុននេះដែរឬទេ ? (សូមមើលគំរោងដែលអ្នកបានកត់ទុក នៅក្នុងវគ្គសិក្សាមុននេះ) ។
- តើកិច្ចការណា ដែលបានលទ្ធផលល្អ ? ព្រោះអ្វី ? តើអ្នកអាចធ្វើអោយកិច្ចការនោះកាន់តែបានលទ្ធផលល្អជាងមុន ដោយរបៀបណា ? ។
- តើមានបញ្ហាដែរឬទេ ? ព្រោះអ្វី ? តើអ្នកត្រូវធ្វើដូចម្តេច ? ។
- តើពេលនេះ ក្រុមអ្នកត្រូវចាប់ផ្តើមសកម្មភាពណាមួយរបស់ « តារាងសកម្មភាព » ? តើអ្នកគ្រាន់តែបន្តបំពេញសកម្មភាព ដែលកំពុងធ្វើ ឬមួយចាប់ផ្តើមសកម្មភាពថ្មីមួយទៀត ? ។
- អ្នកបានជ្រើសយកសកម្មភាពមួយរួចហើយ តើពេលនេះ « កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស) » ដែលមានដាក់ជូនខាងក្រោមសកម្មភាពនោះណាខ្លះ ដែលក្រុមអ្នកត្រូវយកទៅបំពេញ ? ។



ពិនិត្យមើលឡើងវិញអំពីការសិក្សា ដែលបានសិក្សារួចហើយ

អ្នកអាចសុំអោយនិស្សិតប្រាប់អ្នកពីអ្វីៗ ដែលគេបានចេះដឹងពីការសិក្សា ដែលគេបានយល់ព្រមរៀន នៅក្នុងវគ្គសិក្សាពីមុនមក ។ អ្នកក៏ត្រូវពិនិត្យមើល**កូនស្បៃវិភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល** ទាំងមូល ដែលនិស្សិតសរសេរចំលើយចំពោះសំនួរ ដែលនៅក្នុងកូនសៀវភៅនោះដែរ ។

ដាក់ការសិក្សាថ្មីអោយនិស្សិត

ជ្រើសយក « បទព្រះគម្ពីរ » និង « កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល » (ដែលមានដាក់ជូនក្រោមផ្នែក**ការសិក្សាសំរាប់ជ្រើសរើស**) ដែលត្រូវនឹងផែនការរបស់និស្សិត ។

សូមកត់សំគាល់ពីរបៀបដែលគ្រូបង្ហាត់ជ្រើសរើស « កូនសៀវភៅសំរាប់គ្រូគង្វាលសិក្សា » មួយ ដែលជួយដល់ផែនការរបស់និស្សិត :



យើងសូមបញ្ជាក់ម្តងទៀតថា ផែនការរបស់និស្សិត ត្រូវតែ**ជាក់លាក់** :

គំរោងជាក់លាក់ និង ច្បាស់លាស់ :

ថ្ងៃ ខែ : ១២/៩/២០០២

កិច្ចការឃ្វាល :

ក- អធិស្ឋានរាល់ថ្ងៃ សូមឱ្យគ្រួសារលោកបុល និង គ្រួសារលោកពៅថ្វាយខ្លួន ។

ខ- ល្ងាចថ្ងៃអាទិត្យ ទៅសួរសុខទុក្ខគ្រួសារទាំងពីរ ហើយប្រើសៀវភៅ ទី ១ « ដំណឹងល្អបំផុត » ។

គ- ល្ងាចថ្ងៃសៅរ៍ នាំប៉ុនទៅសួរសុខទុក្ខអ្នករស់នៅម្តុំបឹងកក់ ដើម្បីបង្កើតទំនាក់ទំនងថ្មី ។

ការសិក្សា :

ក- កូនសៀវភៅ ទី ២ « របៀបផ្សព្វផ្សាយដំណឹងល្អ » ។

ខ- អានសៀវភៅដំណឹងល្អម៉ាកុស ។

ការប្រជុំលើកក្រោយ :

ថ្ងៃព្រហស្បតិ៍ ទី ២៤ ម៉ោង ៧:៣០ព្រឹក នៅកន្លែងខ្ញុំ ។

គំរោងមិនជាក់លាក់ :

វិច្ឆិកា

កិច្ចការឃ្វាល :

ក- អធិស្ឋានច្រើន

ខ- អាទិត្យក្រោយ ផ្សាយដំណឹងល្អ

ការសិក្សា :

ក- កូនសៀវភៅកិរិត ទី ១

ខ- អានម៉ាកុស

ការប្រជុំលើកក្រោយ :

ពេលគ្រូបង្ហាត់មានពេលទំនេរ ហើយជួបគ្នានៅកន្លែងខ្ញុំ

សេចក្តីសង្ខេប

នៅក្នុងវគ្គបង្ហាត់បង្រៀននិមួយៗ ត្រូវមានការអធិស្ឋាន និងកិច្ចការខាងក្រោមនេះ :

	ការវាយតម្លៃ	**ផែនការ**
កិច្ចការដែលត្រូវអនុវត្ត	គ្រូបង្ហាត់ស្តាប់របាយការណ៍របស់និស្សិតអំពីកិច្ចការ ដែលនិស្សិតបានបំពេញរួចហើយ ជាមួយក្រុមជំនុំ ឬ ក្រុមរបស់គេ ។	និស្សិតរៀបចំគំរោងសំរាប់ជំហានបន្ទាប់ ដែលត្រូវយកទៅអនុវត្តជាមួយហ្វូងចៀមរបស់គេ ។
ការសិក្សា	គ្រូបង្ហាត់ស្តាប់ ឬ មើលទាំងអស់អំពីការសិក្សា ដែលនិស្សិតបានសិក្សារួចហើយ ។	គ្រូបង្ហាត់ និង និស្សិតជ្រើសរើសការសិក្សាថ្មីៗ ដែលទាក់ទងនឹងផែនការដែលគេចង់អនុវត្ត ។

សូមបងប្អូននឹកចាំថា សៀវភៅនេះជាសៀវភៅណែនាំ ។ សៀវភៅនេះនឹងជួយអ្នកអោយអាចណែនាំការងារ និងការសិក្សារបស់និស្សិត ។ សូមប្រើសៀវភៅនេះ តាមការណែនាំទាំងអស់របស់សៀវភៅនេះ ប៉ុន្តែ ក៏ត្រូវមានគំនិតឆ្នៃប្រឌិតដែរ ! ។

ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ អ្នកអាចបង្រៀន និងពន្យល់គោលការណ៍របស់សៀវភៅណែនាំនេះដល់និស្សិតគ្រូគង្វាល ។ អ្នកអាចប្រើ **"កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)"** និង **"ការសិក្សា (សំរាប់ជ្រើសរើស)"**បន្ថែម ដែលគ្មាននៅក្នុងសៀវភៅណែនាំនេះក៏បានដែរ ។ សេចក្តីសំខាន់ គឺ "បង្ហាត់បង្រៀន" និស្សិតរបស់អ្នក តាមរបៀបមួយ ដែលនាំអោយអ្នក និង ក្រុមជំនុំ "កើនចំនួនបន្ត" ។

សូមអោយព្រះជាម្ចាស់ប្រទានកំឡាំងអោយអ្នក ពេលអ្នកធ្វើការងារ ! ។



លិខិតចុះពត៌មានរបស់និស្សិត

ឈ្មោះរបស់និស្សិតគ្រួគង្វាល : _____

អាស័យដ្ឋាន : _____

ក្រុមជំនុំរបស់និស្សិតគ្រួគង្វាល : _____

ថ្ងៃ ខែ កំណើត : _____

ថ្ងៃ ខែ ថ្វាយខ្លួន : _____

មានគ្រួសារ / នៅលីវ : _____

ការសិក្សាព្រះគម្ពីរពីមុន : _____

ការសិក្សាទូទៅពីមុន : _____

គោលដៅរបស់ក្រុមជំនុំ ឬក្រុមរបស់និស្សិតគ្រួគង្វាលសំរាប់ប្រាំឆ្នាំទៅមុខ (ដូចជាការរីកចំរើន ការបង្កើតក្រុមជំនុំថ្មី ការបង្កើតកិច្ចការបំរើថ្មី ។ល។) :

_____

_____

_____

កិច្ចការបំរើខ្លះដែលនិស្សិតគ្រួគង្វាលត្រូវបំពេញ នៅក្នុងរយៈពេលហាត់រៀនក្នុងកម្មវិធីនេះ :

_____

_____

_____

_____

ផ្នែកសកម្មភាព

ស-១ អធិស្ឋាន និង រៀបចំផែនការដោយជំនឿ

កំណត់ចំណាំដ៏សំខាន់សំរាប់គ្រូបង្ហាត់ :

ចូរចងចាំថា អ្នកសិក្សាត្រូវធ្វើ «កិច្ចការដែលត្រូវអនុវត្ត» រួមជាមួយក្រុម ឬ ក្រុមជំនុំដែលគេដឹកនាំ ។ បើសិនជាអ្នកសិក្សាមិនទាន់មានក្រុមនៅឡើយ នោះគេត្រូវផ្សព្វផ្សាយដំណឹងល្អ ដើម្បីបង្កើតអោយបានក្រុមមួយ ។ គ្រូបង្ហាត់ត្រូវត្រួតពិនិត្យការងាររបស់អ្នកសិក្សា ។

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

☐ ដោយយកក្ងនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ២៤ «ការហាត់រៀនធ្វើជាគ្រូគង្វាល» ដែលជាក្ងនសៀវភៅសំរាប់នាំអោយស្គាល់ដំណើរការសិក្សាក្នុងកម្មវិធី «បង្ហាត់បង្រៀន និងបង្កើនចំនួនបន្ត»™ និស្សិតត្រូវស្វែងរកព្រះហឫទ័យព្រះជាម្ចាស់អំពីទីកន្លែង និង របៀបដែលគេត្រូវចាប់ផ្តើមមុខងារបំរើរបស់គេ ។ គ្រូបង្ហាត់កិច្ចការឃ្វាលត្រូវណែនាំនិស្សិតគ្រូគង្វាល ក្នុងដំណើរការនេះ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

☐ សិក្សាក្នុង កិច្ចការ ជំពូក ១០ អំពីរបៀបដែលព្រះជាម្ចាស់ដឹកនាំពួកអ្នកដឹកនាំ ។

☐ សិក្សាក្នុង នេហេមី ជំពូក ១ ដល់ ៦ អំពីរបៀបដែលអ្នកដឹកនាំម្នាក់ ធ្វើអោយផែនការបានសំរេច ។

ក្ងនស្សៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ២០ «នេហេមី : របៀបធ្វើអោយបានសំរេចកិច្ចការធំៗ»

☐ ២៤ «ការហាត់រៀនធ្វើជាគ្រូគង្វាល»

ការអានបន្ថែម :

ស-២ មានជ័យជំនះដោយសារការអធិស្ឋាន

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ យកចិត្តទុកដាក់អធិស្ឋាន សិក្សាព្រះបន្ទូល និងប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ។
- ☐ អធិស្ឋានសូមអោយមនុស្សជាច្រើនថ្វាយខ្លួន និងសូមអោយដំណឹងល្អបានរីកសាយ ។
- ☐ ចាប់ផ្តើមកត់ត្រាអំពីសំណូមពរអធិស្ឋាន និងចំលើយចំពោះការអធិស្ឋានទាំងនោះ ។
- ☐ ពង្រឹងកិច្ចការបំរើក្នុងក្រុមជំនុំខាងការអធិស្ឋានទូលអង្វរអោយអ្នកដទៃ ។
- ☐ បង្រៀនអោយចេះអធិស្ឋាន និង តមអាហារ ។
- ☐ អធិស្ឋានសំរាប់អ្នកជំងឺ និងមនុស្សនៅក្រោមអំណាចអារក្ស (សូមមើលសកម្មភាព ស-៥) ។ អធិស្ឋានសំរាប់សេចក្តីត្រូវការរបស់មនុស្ស ដែលអ្នកទើបនឹងជួបទាក់ទងថ្មី ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង ២ របាក្សត្រ ១:៦-១២ : អំពីសេចក្តីដែលអ្នកដឹកនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវស្វែងរក ។
- ☐ សិក្សាក្នុង ម៉ាថាយ ៩:៣៧-៣៨, អេភេសូ ៦:១៨-២០, ២ ថេស្សាឡូនិក ៣:១-២ : អំពីរបៀបដែលយើងត្រូវអធិស្ឋានសំរាប់ការរីកសាយរបស់ដំណឹងល្អ ។
- ☐ សិក្សាក្នុង ម៉ាថាយ ២៦:៣៦-៤៦ : អំពីព្រះយេស៊ូដែលស្តាប់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយការអធិស្ឋាន ។
- ☐ សិក្សាក្នុង កំណើតពិភពលោក ១៨:១៦-៣៣ : អំពីអ្រាហាំដែលមានជ័យជំនះ ដោយសារការអធិស្ឋាន ។
- ☐ សិក្សាក្នុង លូកា ១៨:១-៨ : អំពីសំណូមពរអធិស្ឋានរបស់ស្ត្រីមេម៉ាយ ដែលទទួលចំលើយ ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ១៣ «របៀបអធិស្ឋាន »

☐ ២៥ «ឫទ្ធានុភាពរបស់ព្រះយេស៊ូគ្រីស្ត ដែលគង់ក្នុងយើង »

ការអានបន្ថែម :

ស-៣ ទៅលេងសួរសុខទុក្ខ និង ចែកចាយដំណឹងល្អ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ ធ្វើបញ្ជីកត់ឈ្មោះសាច់ញាតិ និងមិត្តភក្តិរបស់សមាជិក ដែលត្រូវទៅសួរសុខទុក្ខ ហើយនិងអធិស្ឋានអោយពួកគេដោយទៀងទាត់ ។
- ☐ ទៅលេងសួរសុខទុក្ខអ្នកទាំងនោះ និងចែកចាយដំណឹងល្អដោយប្រើមេរៀន « ដំណឹងល្អបំផុត » ឬ មេរៀនផ្សេងទៀត ដែលស្រដៀងគ្នា ។
- ☐ ជួយមេគ្រួសារនិមួយៗដែលយល់ព្រម អោយបង្រៀនពីរឿងក្នុងព្រះគម្ពីរដល់ក្រុមគ្រួសារ និងមិត្តភក្តិរបស់គេ ។
- ☐ នាំអ្នកជឿទៀតទៅជាមួយអ្នក ដើម្បីបង្ហាត់ពួកគេអោយចេះផ្សាយដំណឹងល្អ ។
- ☐ ប្រើវិធីផ្សព្វផ្សាយដំណឹងល្អផ្សេងៗអោយបានច្រើន ដើម្បីស្វែងរកវិធីដែលមានប្រសិទ្ធិភាពជាងគេ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ១-៣ : ការធ្លាក់ចុះទៅក្នុងអំពើបាបរបស់អាដាមបណ្តាលអោយមនុស្សជាតិទាំងអស់ធ្លាក់ចុះទៅក្នុងអំពើបាបដែរ ។
- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ៤ : ការថ្វាយយញ្ញបូជា ជាសត្វឥតស្លាកស្នាម សំរាប់ចេញថ្លៃសងទោសនៃអំពើបាបរបស់មនុស្ស ។
- ☐ សិក្សាក្នុង ម៉ាថាយ ៤:១-១១ : ការប្រព្រឹត្តរបស់អាដាមចំពោះសេចក្តីល្បួង ផ្ទុយពីព្រះ-យេស៊ូ ។
- ☐ សិក្សាក្នុង ម៉ាកុស ជំពូក ១៤-១៦ : សេចក្តីពិស្តារអំពីការរងទុក្ខវេទនា និងជ័យជំនះរបស់ព្រះយេស៊ូ ។

កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ២ «របៀបផ្សព្វផ្សាយដំណឹងល្អដោយប្រើមេរៀន "ដំណឹងល្អបំផុត" »

☐ ១៥ «ព្រះយេស៊ូត្រាស់ហៅអ្នក »

☐ ១៦ «ព្រះយេស៊ូគ្រីស្តឈ្នះលើមារសត្វរបស់យើង »

☐ ១៧ «លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក »

ការអានបន្ថែម :

ស-៤ ធ្វើពិធីជ្រមុជទឹក និង ទទួលពួកអ្នកជឿថ្មី

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ អធិស្ឋានសូមអោយអ្នកជឿថ្មីបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។
- ☐ កំណត់ឈ្មោះអ្នកដែលត្រូវទទួលពិធីជ្រមុជទឹក និង អ្នកដែលត្រូវទទួលអោយចូលជាសមាជិកក្រុមជំនុំ ។
- ☐ រៀបចំទីកន្លែង កាលបរិច្ឆេទ និងកិច្ចការផ្សេងៗសំរាប់ធ្វើពិធីជ្រមុជទឹក ។
- ☐ ធ្វើពិធីជ្រមុជទឹកនៅទីកន្លែង ដែលបានព្រមព្រៀងគ្នាហើយ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ៥-៩ : ចាំបាច់ត្រូវកែប្រែចិត្តគំនិត នៅចំពោះព្រះជាម្ចាស់ដ៏វិសុទ្ធ ។
- ☐ សិក្សាក្នុង សេរីភាព ជំពូក ១៤-១៥ : ពិធីជ្រមុជទឹកជានិមិត្តរូបអំពីពួកកូនចៅអ៊ីស្រាអែលនៅក្នុងសមុទ្រក្រហម ។
- ☐ សិក្សាក្នុង កិច្ចការ ១៦:១៩-៤០ : អ្នកដែលទទួលពិធីជ្រមុជទឹក ត្រូវទទួលនៅពេលណា និងនៅក្នុងលក្ខខ័ណ្ឌណាខ្លះ ។
- ☐ សិក្សាក្នុង រ៉ូម ៥:១២ ដល់ ៦:១៤ : សារៈសំខាន់នៃពិធីជ្រមុជទឹក ក្នុងអង្គព្រះគ្រីស្ត ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

- ☐ ១ «ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី»

ការអានបន្ថែម :

ស-៥ អធិស្ឋានសំរាប់អ្នកជំងឺ និង មនុស្សដែលនៅក្រោមអំណាចអារក្ស

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

☐ រៀបចំខ្លួនអ្នកដើម្បីធ្វើកិច្ចការនេះអោយបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អ្នកណាម្នាក់ដែលធ្លាប់មានបទពិសោធន៍ក្នុងការធ្វើកិច្ចការបំរើពិសេសនេះ ។

☐ ធ្វើអោយចេះបំពេញកិច្ចការបំរើនេះ កាន់តែច្រើនឡើងៗ ដោយធ្វើរួមជាមួយអ្នកណាម្នាក់ដែលធ្លាប់មានបទពិសោធន៍ ក្នុងការធ្វើកិច្ចការបំរើនេះ បើសិនជាអាចធ្វើទៅបាន ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

☐ សិក្សាក្នុង ១ ពង្សាវតារក្សត្រ ជំពូក ១៧ : ការដែលលោកអេលីយ៉ាបានធ្វើចំពោះក្មេងដែលស្លាប់ ។

☐ សិក្សាក្នុង កិច្ចការ ១៦:១៦-១៨ : ការដែលលោកប៉ូលធ្វើ ដើម្បីដេញខ្មោចចេញ ។

☐ សិក្សាក្នុង អេភេសូ ៦:១០-២០ : គោលបំណងរបស់គ្រឿងសស្ត្រាវុធផ្សេងៗរបស់ព្រះជាម្ចាស់ ។

ក្ងនស្បៀរភៅសំរាប់បង្ហាត់បង្រៀនត្រួតង្វាល :

☐ ២៥ « ឫទ្ធានុភាពរបស់ព្រះយេស៊ូគ្រីស្ត ដែលគង់ក្នុងយើង »

ការអានបន្ថែម :

_____

_____

_____

ស-៦ ណែនាំប្រមូលសមាជិកទាំងអស់អោយចូលរួម ក្នុងការផ្សព្វផ្សាយដំណឹងល្អ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ អធិស្ឋានទូលសុំអោយព្រះជាម្ចាស់ធ្វើអោយសមាជិកទាំងអស់របស់ក្រុម ក្លាយទៅជាអ្នកផ្សព្វផ្សាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាព ។
- ☐ រៀបចំកំណត់ពេលវេលាអោយបានល្អ ដើម្បីអាចផ្សព្វផ្សាយដំណឹងល្អរៀងរាល់អាទិត្យ ។
- ☐ ស្វែងរកមនុស្សដែលចាប់អារម្មណ៍លើដំណឹងល្អ ។
- ☐ បង្រៀនអ្នកជឿថ្មីអោយចេះប្រើមេរៀន « ដំណឹងល្អបំផុត » ដែលទាក់ទងនឹងក្លូនសៀភៅ ទី ២ « របៀបផ្សព្វផ្សាយដំណឹងល្អដោយប្រើមេរៀន » ។
- ☐ បង្ហាត់បង្រៀនអ្នកជឿថ្មីអោយចេះផ្សព្វផ្សាយដំណឹងល្អដល់សាច់ញាតិ មិត្តភក្តិ និងអ្នករួមការងាររបស់ពួកគេ ។
- ☐ បង្រៀនអ្នកជឿថ្មីអោយចេះដឹកនាំមនុស្សអោយថ្វាយខ្លួន ដោយប្រើខិត្តប័ណ្ណផ្សាយដំណឹងល្អដូចជា « តើខ្ញុំអាចស្គាល់ព្រះជាម្ចាស់ដោយរបៀបណា ? » (How to Know God by SEAN) ។
- ☐ នៅពេលប្រជុំថ្វាយបង្គំ សូមបញ្ជាក់ពីកិច្ចការផ្សាយដំណឹងល្អ ដែលកំពុងដំណើរការ ។
- ☐ ចាប់ផ្តើមផ្សាយដំណឹងល្អនៅកន្លែងថ្មីៗ ជាពិសេសនៅកន្លែងដែលបងប្អូន និង មិត្តភក្តិរបស់ពួកអ្នកជឿរស់នៅ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង យ៉ូស្វ៉ូអា ១:១-១១ : ការដែលយើងត្រូវធ្វើ ដើម្បីអោយមានជ័យជំនះ ដោយសារព្រះនាមព្រះយេស៊ូ ។
- ☐ សិក្សាក្នុង កំណើតពិភពលោក ១០:១ ដល់ ១២:៣ : ជាតិសាសន៍នានាត្រូវទទួលព្រះពរ ។
- ☐ សិក្សាក្នុង លូកា ១០:១-២៤ : ព្រះយេស៊ូបង្គាប់យើងអោយប្រកាសពីព្រះរាជ្យព្រះអង្គ ។

- ☐ សិក្សាក្នុង លូកា ជំពូក ២៣-២៤ : ដំណើររឿងអំពីដំណឹងល្អ ។
- ☐ សិក្សាក្នុង ម៉ាថាយ ១៣:២៤-៤៣ និង វិវរណ: ២០:១១-១៥ : ការដែលនឹងកើតមានចំពោះពួកអ្នក ដែលមិនទទួលព្រះអម្ចាស់យេស៊ូគ្រីស្ត ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

- ☐ ៤ « ស្តេចដាវីឌ »
- ☐ ៥ « ការផ្សព្វផ្សាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាព »
- ☐ ៨ « មហាបណ្តាំ - បេសកកម្មសកលលោក »
- ☐ ២៦ « វត្តមានរបស់ព្រះគ្រីស្ត និង ការរីកសាយរបស់ក្រុមជំនុំ/ព្រះសហគមន៍ »
- ☐ ៣២ « ការចែកចាយដំណឹងល្អប្រាប់អ្នកដទៃ »

ការអានបន្ថែម :

ស-៧ បង្រៀនអោយចេះរស់នៅតាមជីវិតគ្រីស្តជន

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ បង្រៀនអ្នកជឿថ្មីថា ការចាំបាច់បំផុត គឺត្រូវស្រឡាញ់ព្រះគ្រីស្ត ហើយត្រូវស្គាល់ដឹង និងស្តាប់តាមសេចក្តីបង្គាប់របស់ព្រះអង្គ ។
- ☐ ចាប់ផ្តើមបង្កើតក្រុម «សាវ័កថ្មី» ដោយប្រើមេរៀនជាមូលដ្ឋាន សំរាប់ការបង្រៀនអំពីជីវិតគ្រីស្តជន ដូចជា : «ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត» ដែលទាក់ទងនឹងកូនសៀវភៅទី ៧ «របៀបបង្កើតសាវ័ក» ឬក៏សៀវភៅ «ជីវិតដ៏បរិបូណ៌» (Abundant Life by SEAN) ។
- ☐ ឆ្លើយសំនួរពួកអ្នកជឿថ្មីអំពីជីវិតគ្រីស្តជន និងអំពីក្រុមជំនុំ ហើយជួយពួកគេអោយចេះដាក់ខ្លួនចុះចូលទាំងស្រុងរួមជាមួយគ្រួសាររបស់ពួកគេ ថ្វាយព្រះអម្ចាស់យេស៊ូគ្រីស្តរាល់ថ្ងៃ ។
- ☐ បង្រៀនអំពីតម្លៃនៃការដែលអ្នកជឿថ្មីធ្វើជា «អំបិល និង ពន្លឺ» ដល់ក្រុមគ្រួសារ និងមិត្តភក្តិរបស់គេ ។
- ☐ បញ្ជូលគ្រីស្តជនថ្មីអោយធ្វើការងារ ឬ ធ្វើកិច្ចការបំរើខ្លះៗថ្វាយព្រះអម្ចាស់ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង ម៉ាកុស ១:១៥, ម៉ាថាយ ៤:៤, ៧:៧, ២២:៣៧-៣៩, ២៨:១៩-២០, លូកា ៦:៣៨ និង ២២:១៩-២០ : សេចក្តីបង្គាប់សំខាន់បំផុតរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។
- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ១២-១៩ : សារៈសំខាន់នៃអ្វីៗដែលលោកអប្រាហាំបានធ្វើ ។
- ☐ សិក្សាក្នុង ម៉ាថាយ ជំពូក ៥-៧ : សេចក្តីដែលសាវ័ករបស់ព្រះយេស៊ូត្រូវធ្វើ ។
- ☐ សិក្សាក្នុង ១ ធីម៉ូថេ ៣:១៦-១៧ : គោលបំណងរបស់សេចក្តីបង្រៀនរបស់ព្រះគម្ពីរ ។
- ☐ សិក្សាក្នុង ម៉ាកុសទាំងមូល : ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជីវិតរបស់ព្រះយេស៊ូ ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ៧ «របៀបបង្កើតសាវ័ក ដោយប្រើមេរៀន"ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត" »

☐ ៣០ «សេចក្តីបង្គាប់ទាំងប្រាំពីរ »

☐ ៣៣ «កិច្ចការរបស់ព្រះជាម្ចាស់ជាព្រះវិញ្ញាណដ៏វិសុទ្ធ »

ការអានបន្ថែម :

ស-៨ បណ្តុះអោយមានសេចក្តីស្រឡាញ់ ចំពោះព្រះជាម្ចាស់ និង មនុស្សឯទៀត

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ បង្រៀន និងអនុវត្តតាមប្រស្នាអំពីអ្នកស្រុកសាម៉ារីម្នាក់ ដែលមានចិត្តសប្បុរស ។
- ☐ ចាប់ផ្តើមកំណត់រក និងដោះស្រាយបញ្ហាខ្លះ នៅក្នុងចំណោមមនុស្សដែលរស់នៅក្បែរសមាជិកក្រុមជំនុំ ឬ ក្រុមតូច ។
- ☐ ណែនាំប្រមូលអ្នកជឿខ្លះអោយចូលរួមក្នុងគំរោងកម្មវិធីសាមញ្ញៗ ដែលមានគោលដៅជួយពួកអ្នកជិតខាងរបស់ពួកគេ ។
- ☐ ជួយពួកអ្នកជឿថ្មីអោយចូលរួមជាមួយក្រុមជំនុំ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង ១ សាមូអែល ជំពូក ២៤ : ស្តេចដាវីឌបង្ហាញសេចក្តីស្រឡាញ់ចំពោះខ្មាំងសត្រូវ ។
- ☐ សិក្សាក្នុង លូកា ១០:២៥-៣៧ : របៀបបង្ហាញសេចក្តីស្រឡាញ់ពិតចំពោះអ្នកជិតខាង ។
- ☐ សិក្សាក្នុង ១ យ៉ូហានទាំងមូល : សេចក្តីបង្រៀនអំពីសេចក្តីស្រឡាញ់ ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល :

- ☐ ១៩ «ការចែកចាយសេចក្តីស្រឡាញ់ដល់អ្នកជឿថ្មី»
- ☐ ២១ «អ្នកជិតខាងរបស់ខ្ញុំ»

ការអានបន្ថែម :

ស-៩ បង្រៀនអោយចេះអាន និង ប្រតិបត្តិតាមព្រះគម្ពីរ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ បង្រៀនអោយគេយល់សេចក្តីសំខាន់ៗ នៅក្នុងខ្លឹមសាររបស់ព្រះគម្ពីរ ។
- ☐ បង្រៀនអោយគេចេះប្រតិបត្តិតាមព្រះគម្ពីរ ដោយទុកព្រះគម្ពីរជាផ្លូវជីវិត ។
- ☐ នាំអោយគេចេះអាន និង អនុវត្តតាមព្រះគម្ពីរប្រចាំថ្ងៃ ។
- ☐ រៀបចំក្រុមសិក្សាព្រះគម្ពីរ ដោយប្រើសំភារៈ ដូចជា «សៀវភៅដែលនាំឱ្យស្គាល់ព្រះគម្ពីរ» (Bible Encounter Manual by SEAN) ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង នេហេមី ជំពូក ៨ : កិច្ចការដែលគេបានធ្វើ ដើម្បីអោយមនុស្សយកព្រះគម្ពីរមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ។
- ☐ សិក្សាក្នុង ម៉ាថាយ ៧:២៤-២៦ : ការដែលត្រូវកើតឡើង បើសិនជាគ្រាន់តែស្តាប់ព្រះគម្ពីរ តែមិនយកទៅអនុវត្ត ។
- ☐ សិក្សាក្នុង ម៉ាថាយ ១៥:១-២០ : បញ្ហាដែលនឹងកើតមានក្នុងជីវិតមនុស្ស បើសិនជាពួកគេយកព្រះបន្ទូលព្រះជាម្ចាស់ទៅបំភ្លៃខុសពីន័យពិត ឬ យកទៅប្រើផ្តេសផ្តាស ។
- ☐ សិក្សាក្នុង ១ ពេត្រុស ១:២២ ដល់ ២:៣ : តម្លៃរបស់ព្រះបន្ទូលព្រះជាម្ចាស់ក្នុងជីវិតរបស់យើង ។
- ☐ សិក្សាក្នុង វិវរណៈ ២២:១៨-១៩ : ការព្រមានចំពោះពួកអ្នកដែលកែប្រែព្រះបន្ទូលព្រះជាម្ចាស់ ។

កូនស្សេរភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល :

☐ ៩ «ព្រឹត្តិការណ៍សំខាន់ៗ»

☐ ១៤ «របៀបសិក្សាព្រះគម្ពីរ»

ការអានបន្ថែម :

«ពន្លឺរបស់ព្រះគម្ពីរ» (The Light of the Bible by SEAN) _____

ស-១០ ជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់

កំណត់ចំណាំដ៏សំខាន់សំរាប់គ្រូបង្ហាត់ :

នៅក្នុងក្រុមជំនុំថ្មី ជាដំបូង ពួកអ្នកសិក្សាត្រូវរៀនអោយចេះដឹកនាំការថ្វាយបង្គំ នៅក្នុងក្រុមតូច ក្រោមការណែនាំរបស់គ្រូបង្ហាត់សិន ។ នៅពេលដែលគេអញ្ជើញមនុស្សទូទៅអោយមកថ្វាយបង្គំ នោះត្រូវអោយនរណាម្នាក់ដែលរស់នៅក្នុងតំបន់នោះ ធ្វើជាអ្នកដឹកនាំនៃការប្រជុំថ្វាយបង្គំ ។ បើសិនជាអ្នកសិក្សាដែលដឹកនាំការថ្វាយបង្គំជាគ្រីស្តជនថ្មី សូមតម្រូវអោយអ្នកសិក្សានោះឡើងមកនិយាយ ឬ លើកយកខគម្ពីរមកចែកចាយក្នុងរយៈពេលខ្លីៗប៉ុណ្ណោះ ។

គ្រូបង្ហាត់មិនគួរដឹកនាំការថ្វាយបង្គំទេ ពីព្រោះបើគ្រូដឹកនាំ នោះនឹងធ្វើអោយអ្នកសិក្សាមិនចេះទទួលខុសត្រូវ ឬក៏មិនចេះផ្តួចផ្តើមធ្វើកិច្ចការបំរើដោយខ្លួនឯង ។ បើសិនជាក្រុមជំនុំជួបជុំនៅផ្ទះអ្នកណាម្នាក់ ការល្អបំផុត គឺមិនត្រូវអោយមេគ្រួសារដឹកនាំការប្រជុំទេ ព្រោះសមាជិកអាចគិតថាក្រុមជំនុំ «ជារបស់» មេគ្រួសារនោះ ហើយសមាជិកអាចមានគំនិតថា គេមិនបាច់ផ្តួចផ្តើមគំនិតធ្វើអ្វីៗ ឬក៏ទទួលខុសត្រូវអ្វីទាំងអស់ គឺថា អ្នកចូលរួមធ្វើកិច្ចការទាំងអស់លើមេគ្រួសារនោះ ។

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ អធិស្ឋានទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំការថ្វាយបង្គំ ។
- ☐ រៀបចំការប្រជុំថ្វាយបង្គំឱ្យបានមុនច្រើនថ្ងៃ រួមជាមួយអ្នកដឹកនាំឯទៀត និងអ្នកលេងភ្លេង ។
- ☐ ប្រជុំគ្នានៅកន្លែងដែលសមរម្យសំរាប់ថ្វាយបង្គំព្រះជាម្ចាស់ (ដូចជា ផ្ទះ ទីធ្លាក្បែរផ្ទះ ឬរោងនៅទីវាល អាគារ សាលារៀន អាគារព្រះវិហារ ជាដើម) ។
- ☐ រៀបចំធ្វើការប្រជុំថ្វាយបង្គំប្រកបដោយភាពកក់ក្តៅ និងការលើកទឹកចិត្ត ដែលគ្រប់គ្នាអាចចូលរួមថ្វាយបង្គំ ស្របតាមអំណោយទានរបស់ខ្លួន ។
- ☐ រៀបចំអោយបានល្អ ដើម្បីអោយអ្នកជឿគ្រប់គ្នាអាចចូលរួមក្នុងពិធីកាច់នំប៉័ង ។
- ☐ ធ្វើអោយការថ្វាយបង្គំមានរបៀបរបប ស្របទៅតាមវប្បធម៌របស់ទីកន្លែង ដើម្បីអោយអ្នកចូលរួមទាំងអស់ស្រួលក្នុងចិត្ត ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ២០-៣៦ : អាកប្បកិរិយាត្រឹមត្រូវសំរាប់ការថ្វាយបង្គំ ។
- ☐ សិក្សាក្នុង សេរីភាព ជំពូក ១៦-១៧ : របៀបទទួលអ្វីៗដែលព្រះជាម្ចាស់ប្រទានអោយ ។ (ប្រៀបធៀបសេរីភាពនេះជាមួយនឹងយ៉ូហាន ជំពូក ៥-៦) ។
- ☐ សិក្សាក្នុង សេរីភាព ជំពូក ២៧ និង ៣៣:៧-១០ : ការរៀបរាប់ពិស្តារអំពីព្រះពន្លា និងភាពជាសង្ឃ ។
- ☐ សិក្សាក្នុង ទំនុកតម្កើង ជំពូក ១០០ : របៀបដែលយើងចូលទៅចំពោះព្រះជាម្ចាស់ ។
- ☐ សិក្សាក្នុង កិច្ចការ ២:៣៦-៤៧ : ការរៀបរាប់អំពីការប្រជុំថ្វាយបង្គំនៅក្នុងក្រុមជំនុំដំបូង ។
- ☐ សិក្សាក្នុង ១ កូរិនថូស ជំពូក ១១ និង ហេប្រឺ ១០:២៥ : គោលការណ៍សំរាប់ការដឹកនាំ និងការចូលរួមក្នុងការថ្វាយបង្គំ ។

កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

- ☐ ១១ « ព្រះឯកត្រីអង្គដ៏វិសុទ្ធ »
- ☐ ១២ « ក្រុមជំនុំតាមផ្ទះ »
- ☐ ១៣ « របៀបអធិស្ឋាន »
- ☐ ១៨ « ពិធីកាច់នំប៉័ង »
- ☐ ៣១ « ច្រៀងចំរៀងថ្វាយព្រះអម្ចាស់ »
- ☐ ៣៤ « ការថ្វាយបង្គំព្រះជាម្ចាស់ដ៏ខ្ពស់បំផុត »

ការអានបន្ថែម :

ស-១១ ថ្វាយបង្គំក្នុងក្រុមគ្រួសារ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

☐ បង្រៀនសមាជិកអោយចេះអធិស្ឋាន និងសិក្សាព្រះគម្ពីរ ដោយទៀងទាត់ជាមួយក្រុមគ្រួសារ របស់គេ ។

☐ បង្រៀនក្រុមគ្រួសារអោយចេះថ្វាយបង្គំផ្ទុសចេញពីចិត្តជាមួយគ្នា គឺអោយមានការអធិស្ឋានរវាង ប្តីប្រពន្ធ និង រវាងឪពុកម្តាយ និង កូន (ឧទាហរណ៍ : ពេលព្រលឹម ឬ ពេលលាច) ។

☐ ប្រជុំអធិស្ឋានពិសេស សំរាប់កសាងក្រុមគ្រួសារទាំងអស់ អោយរីកចំរើនឡើង ។ (ដូចជាទៅ កំពង់សោមពីរបីថ្ងៃ ដើម្បីកំសាន្តចិត្ត និង អធិស្ឋានច្រើន) ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

☐ សិក្សាក្នុង យ៉ូស្វ៊ូអា ២៤:១៥ និង យ៉ូប ១:៥ : កិច្ចការដែលយ៉ូស្វ៊ូអា និងយ៉ូបធ្វើចំពោះកូនៗ របស់គាត់ ។

☐ សិក្សាក្នុង លូកា ១៨:១៥-១៧ និង អេភេសូ ៦:៤ : កិច្ចការដែលយើងត្រូវធ្វើចំពោះកូនៗ របស់យើង ។

☐ សិក្សាក្នុង យ៉ូហានទាំងមូល : ព្រឹត្តិការណ៍នៅក្នុងជីវិតរបស់ព្រះយេស៊ូសំរាប់យកទៅបង្ហាត់ កុមារ ។

កូនស្បៃវែកសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ៦ « ការអធិស្ឋានក្នុងក្រុមគ្រួសារ »

ការអានបន្ថែម :

_____

_____

_____

ស-១២ រៀបចំក្រុមជំនុំ និង ការដឹកនាំក្នុងក្រុមជំនុំ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ អធិស្ឋានសុំឱ្យព្រះជាម្ចាស់ណែនាំបង្ហាញអ្នក ពីមនុស្សដែលគួរធ្វើជាអ្នកដឹកនាំក្នុងក្រុមជំនុំ ។
- ☐ វាយតំលៃការរីកចំរើនរបស់ក្រុមអ្នកដឹកនាំ និងវិភាគលើសកម្មភាពជាប្រចាំរបស់ពួកគេ ។
- ☐ តែងតាំងអ្នកដឹកនាំ (អ្នកចាស់ទុំ = គ្រូគង្វាល ឬ គ្រូគង្វាលជំនួយ) ។ អ្នកដឹកនាំម្នាក់ៗទាំងនេះ ត្រូវចូលរួមចំណែកក្នុងកិច្ចការឃ្វាល ។
- ☐ ជួយអ្នកដឹកនាំ (អ្នកចាស់ទុំ)អោយប្រជុំគ្នាជាទៀងទាត់ ដើម្បីចាត់ចែងការងារ (ដូចជាការផ្សព្វផ្សាយដំណឹងល្អ ការជួយពួកអ្នកជឿថ្មីអោយក្លាយជាសាវ័ក ការថ្វាយបង្គំ ការជួយពួកអ្នកដែលខ្វះខាត បេសកកម្មគ្រីស្តទូត ។ល។) ។
- ☐ វាយតំលៃអំណោយទានរបស់សមាជិក ហើយបែងចែកការទទួលខុសត្រូវ តាមអំណោយទាននេះ ។
- ☐ កត់ឈ្មោះអ្នកដែលចូលរួមក្នុងការប្រជុំផ្សេងៗ និងធ្វើបញ្ជីឈ្មោះអ្នកទទួលពិធីជ្រមុជទឹក និងបញ្ជីឈ្មោះសមាជិក ។
- ☐ ជួយក្រុមជំនុំតែងតាំងហេរញ្ញិក និង អ្នកជំនួយហេរញ្ញិក ដើម្បីធ្វើគំរោងថវិកា និង ធ្វើបញ្ជីចំណូលចំណាយ បើសិនជាអ្នកមិនទាន់មាន ។

កំណត់ចំណាំ : ចុះឈ្មោះ និងទទួលពួកអ្នកចាស់ទុំថ្មីក្នុងកម្មវិធីបង្ហាត់បង្រៀននិស្សិតគ្រូគង្វាលនេះ (សូមមើលសកម្មភាព ស-១៦) ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង លូកា ៦:១២-១៦ : របៀបដែលព្រះយេស៊ូជ្រើសរើសសាវ័ករបស់ព្រះអង្គ ។
- ☐ សិក្សាក្នុង សេរីភាព ១៨:១៣-២៧ និង នេហេមី ជំពូក ១-៤ : របៀបចែកកិច្ចការគ្នាធ្វើ ដើម្បីអោយបានសំរេចគោលដៅ ។
- ☐ សិក្សាក្នុង សេរីភាព ១៨:១៣-២៧ និង នេហេមី ជំពូក ១-៤ : របៀបចែកកិច្ចការគ្នាធ្វើ ដើម្បីអោយបានសំរេចគោលដៅ ។
- ☐ សិក្សាក្នុង កិច្ចការ ជំពូក ១-១២ : ឧទាហរណ៍អំពីរបៀបរៀបចំជីវិតរបស់ក្រុមជំនុំ ។

ភ្ជួនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល :

- ☐ ៣ «អ្នកធ្វើអំណោយដោយចិត្តអំណរ» (បើសិនជាពួកគេត្រូវការជំនួយអំពីការធ្វើថវិកា)
- ☐ ២៣«ការរៀបចំជារូបកាយរបស់ព្រះគ្រីស្ត»

ការអានបន្ថែម :

ស-១៣ បង្កើតអោយមានការប្រកបគ្នាក្នុងក្រុមជំនុំ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ ប្រមូលសមាជិកអោយប្រកបគ្នា និង បរិភោគចំណីអាហារជាមួយគ្នា ។
- ☐ បង្កើតកម្មវិធីលំហែសុខភាពសំរាប់ក្រុមជំនុំ ។
- ☐ បង្រៀនអំពីតំលៃនៃការប្រកបគ្នារវាងក្រុមគ្រួសារជាច្រើនរបស់ក្រុមជំនុំ និងអំពីតំលៃនៃការធ្វើសកម្មភាពក្នុងបរិយាកាសរីករាយ និងធ្ងរស្រាល ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ជំពូក ៣៧-៥០ : សេចក្តីស្រឡាញ់របស់យ៉ូសែបចំពោះគ្រួសារគាត់ (និយាយអំពីដំណើរជីវិតរបស់គាត់) ។
- ☐ សិក្សាក្នុង ១ កូរិនថូស ១១:២៣-៣៤ : គំរូអំពីកម្មវិធីថ្វាយបង្គំ ។
- ☐ សិក្សាក្នុង យ៉ូហាន ១៣:៣៤-៣៥, អេភេសូ ៤:៣១-៣២, ១ យ៉ូហានទាំងមូល : គោលការណ៍សំរាប់ការប្រកបគ្នារបស់គ្រីស្តជន ។
- ☐ សិក្សាក្នុង អេភេសូទាំងមូល : របៀបបណ្តុះសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និង ចំពោះអ្នកដទៃ ។

ក្លូនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល :

- ☐ ២១ «អ្នកជិតខាងរបស់ខ្ញុំ»

ការអានបន្ថែម :

ស-១៤ សួរសុខទុក្ខ និង លើកទឹកចិត្តសមាជិក

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ រៀបចំធ្វើគំរោង ដើម្បីទៅសួរសុខទុក្ខសមាជិករបស់ក្រុមជំនុំទាំងអស់ ។
- ☐ ចាត់ក្រុមតូចមួយអោយទៅសួរសុខទុក្ខសមាជិក ដែលកំពុងជួបទុក្ខលំបាក ។
- ☐ ពេលអ្នកទៅសួរសុខទុក្ខ សូមនាំសមាជិកទៅជាមួយ ដើម្បីបង្រៀនគេពីរបៀបសួរសុខទុក្ខដែរ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ១៨:១-១៥ : សេចក្តីដែលទេវទូតសន្យាចំពោះលោកអប្រាហាំ និង នាងសារ៉ា ។
- ☐ សិក្សាក្នុង កិច្ចការ ៩:៣៦-៤៣ (ប្រៀបធៀបនឹងយ៉ាកុប ១:២៧) : មូលហេតុដែលនាំឱ្យលោកពេត្រុសទៅសួរសុខទុក្ខនាងឌ័រកាស ។

ក្ងនស្បៀរភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

- ☐ ២២ « ការប្រតិបត្តិតាមព្រះគ្រីស្ត »
- ☐ ២៩ « ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុនសិន »

ការអានបន្ថែម :

_____

_____

_____

_____

ស-១៥ បង្កើតអោយមានការចាត់ចែងថវិកា/ ការថ្វាយដង្វាយក្នុងក្រុមជំនុំ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ បង្រៀនពីអត្ថប្រយោជន៍នៃការដាក់ដង្វាយដប់ភាគរយ និង ការថ្វាយដោយចិត្តសប្បុរស ។
- ☐ ជួយក្រុមជំនុំតែងតាំងហេរញ្ញិក និងអ្នកជំនួយហេរញ្ញិក ដើម្បីធ្វើបញ្ជីចំណូល និងចំណាយ ។
- ☐ ធ្វើគំរោងថវិកា ស្របតាមចំណូលដែលអាចទទួលបាន និងចំណាយដែលបានគ្រោងទុក ដោយគិតទាំងជំនួយផ្គត់ផ្គង់គ្រីស្តទូតដែលធ្វើការក្នុងចំណោមប្រជាជន ក្នុងពិភពលោក ដែលមិនទាន់បានឮដំណឹងល្អទៀតផង ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ១៤:១៧-២៤ (ប្រៀបធៀបនឹងម៉ាឡាគី ៣:១០) : អ្វីៗដែលលោកអប្រាហាំថ្វាយទៅសង្ឃមែលគីសេដែក ។
- ☐ សិក្សាក្នុង សេរីភាព ជំពូក ៣៥-៣៦ : មូលហេតុដែលនាំអោយលោកម៉ូសេប្រាប់អោយបណ្តាជនឈប់ដាក់ដង្វាយ ។
- ☐ សិក្សាក្នុង លូកា ២១:១-៤ : ទឹកព្រះទ័យរបស់ព្រះជាម្ចាស់ចំពោះយើង ដែលថ្វាយទៅព្រះអង្គ ។
- ☐ សិក្សាក្នុង កិច្ចការ ៨:៤-២៥ (ប្រៀបធៀបនឹង ២ កូរិនថូស ៩:៦-៨) : អាកប្បកិរិយាត្រឹមត្រូវ ក្នុងការដាក់ដង្វាយ ។

ក្ងនស្បៀរភៅសំរាប់បង្ហាត់បង្រៀនត្រួតង្វាល :

- ☐ ៣ «អ្នកធ្វើអំណោយដោយចិត្តអំណរ»

ការអានបន្ថែម : _____

ស-១៦ ជ្រើសរើសនិស្សិតគ្រូគង្វាលថ្មី

កំណត់ចំណាំសំរាប់គ្រូបង្ហាត់ :

ការជ្រើសរើសនិស្សិតគ្រូគង្វាលថ្មី ត្រូវធ្វើជាបន្តរហូត នៅក្នុងរយៈពេលដំណើរការកម្មវិធីនេះ ។ ត្រូវអនុវត្តសកម្មភាពនេះ នៅរាល់ពេលដែលមើលឃើញថា មានមនុស្សដែលអាចក្លាយជានិស្សិតគ្រូគង្វាលថ្មី ។ នៅចុងបញ្ចប់កិរិត ទី ១ នេះ អ្នកសិក្សាខ្លួនឯង ត្រូវចាប់ផ្តើមបង្ហាត់បង្រៀននិស្សិតគ្រូគង្វាលថ្មីៗទៀត ។ បើសិនជាគ្រូបង្ហាត់យល់ថា អ្នកសិក្សាមិនទាន់មានសមត្ថភាពធ្វើជាគ្រូបង្ហាត់កិច្ចការឃ្វាលទេ នោះគ្រូបង្ហាត់ខ្លួនឯងអាចទទួលភារៈកិច្ចនេះ ។ សកម្មភាពនេះ ត្រូវអនុវត្តសាឡើងវិញ នៅក្នុងកិរិត ទី ២ ដើម្បីអោយអ្នកសិក្សាខ្លួនឯងមានឱកាសម្តងទៀត អាចក្លាយទៅជាគ្រូបង្ហាត់និស្សិតគ្រូគង្វាលថ្មី ។ ធ្វើដូចនេះ ទើបមានការបង្ហាត់បង្រៀនគ្រូគង្វាលថ្មីជាបន្តរហូត ដែលធ្វើអោយក្រុមជំនុំកើនចំនួនកាន់តែច្រើនឡើងៗ ។

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ អធិស្ឋានទូលសូមព្រះជាម្ចាស់អោយអ្នកអាចជ្រើសរើសបានមនុស្ស ដែលអាចក្លាយជានិស្សិតគ្រូគង្វាលថ្មីពីរ ឬ បីនាក់ ដែលបានទទួលការត្រាស់ហៅរបស់ព្រះជាម្ចាស់ និងមានលក្ខណៈស្របតាមតម្រូវការ ។
- ☐ ធ្វើការសំរេចជាមួយគ្នាអំពីកិច្ចការឃ្វាល ដែលអ្នកសិក្សាអាចយកមកអនុវត្ត (ឧទាហរណ៍ : ចាប់ផ្តើមក្រុមថ្មីមួយ ឬ ក្រុមជំនុំថ្មីមួយ ឬក៏ដឹកនាំក្រុមថ្មីមួយ ឬ ក្រុមជំនុំថ្មីមួយ) ។
- ☐ ទទួលពួកនិស្សិតដែលបានជ្រើសរើសហើយ អោយចូលរួមក្នុង «កម្មវិធីបង្ហាត់បង្រៀន និងបង្កើនចំនួនបន្ត »™ ដោយប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ២៤ «ការហាត់រៀនធ្វើជាគ្រូគង្វាល » ។
- ☐ ចាប់ផ្តើមធ្វើ «កិច្ចការដែលត្រូវអនុវត្ត » «វគ្គបង្ហាត់បង្រៀន » និង «ការសិក្សា » ជាមួយនិស្សិតថ្មី ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង សេរីភាព ជំពូក ១-១០ (ប្រៀបធៀបនឹង ២ ធីម៉ូថេ ២:២) : របៀបដែលព្រះជាម្ចាស់រៀបចំ ត្រាស់ហៅ និង ប្រើលោកម៉ូសេ ។
- ☐ សិក្សាក្នុង ១ ធីម៉ូថេទាំងមូល : គោលការណ៍សំខាន់សំរាប់កិច្ចការឃ្វាល ។
- ☐ សិក្សាក្នុង សេរីភាព ជំពូក ១១-២០ (ប្រៀបធៀបនឹងទីតុស ១:៥) : របៀបដែលលោកម៉ូសេ ណែនាំប្រមូលពួកអ្នកដឹកនាំឯទៀតអោយធ្វើសកម្មភាពដែរ ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

- ☐ ២៤ «ការហាត់រៀនធ្វើជាគ្រូគង្វាល »
- ☐ «សៀវភៅសំរាប់ណែនាំគ្រូបង្ហាត់និស្សិតគ្រូគង្វាល »
- ☐ «សៀវភៅណែនាំសកម្មភាពនិស្សិតគ្រូគង្វាល »នេះ
- ☐ ១-៣៤ «កំរងកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល » ក៏រឹត ទី ១

ការអានបន្ថែម :

ស-១៧ អធិស្ឋានសំរាប់ការផ្សព្វផ្សាយដំណឹងល្អ ក្នុងពិភពលោក

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ ព្យួរផែនទីពិភពលោកមួយលើជញ្ជាំងកន្លែងប្រជុំ ។
- ☐ បង្រៀនពួកអ្នកជឿអំពីភារៈកិច្ចរបស់ពួកគេចំពោះមហាបណ្តាំ ។
- ☐ អធិស្ឋានសំរាប់ការផ្សព្វផ្សាយដំណឹងល្អនៅគ្រប់ទីកន្លែងក្នុងពិភពលោក ដែលមិនទាន់ស្គាល់ព្រះគ្រីស្ត ។
- ☐ ពេលអធិស្ឋាន សូមអធិស្ឋានអោយបានច្រើនអំពីសេចក្តីត្រូវការរបស់ពិភពលោក ។
- ☐ នៅពេលដែលអាចធ្វើបាន សូមទទួលពតិមានពីពួកគ្រីស្តទូត ដែលនៅតំបន់ផ្សេងៗទៀតនៃពិភពលោក ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង កំណើតពិភពលោក ១២:១-៣ (ប្រៀបធៀបនឹងម៉ាថាយ ២៨:១៨-២០) : សេចក្តីសន្យាអំពីការប្រទានព្រះពរចំពោះគ្រប់ជាតិសាសន៍ ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនត្រួតង្វាល :

- ☐ ២៧ « ការចេញទៅផ្សព្វផ្សាយដំណឹងល្អដល់គ្រប់ជាតិសាសន៍ »

ការអានបន្ថែម :

_____

_____

_____

ស-១៨ ពិនិត្យមើលសាឡើងវិញ និង វាយតម្លៃ សកម្មភាពកិរិត ទី ១

នៅក្នុងកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត »™ យើងតែងតែត្រូតពិនិត្យមើលសកម្មភាព ទាំងឡាយជានិច្ច ដើម្បីអោយដឹងច្បាស់ថា ក្រុមជំនុំពិតជា :

- ☐ ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត
- ☐ មានការរីកចំរើនឡើងត្រឹមត្រូវ
- ☐ នៅតែបន្តផ្សព្វផ្សាយដំណឹងល្អ
- ☐ ពង្រីក «ផ្នែកទាំងអស់របស់កិច្ចការឃ្វាល » (សូមមើលសេចក្តីខាងក្រោម)
- ☐ មិននៅទ្រឹងមួយកន្លែង តែបន្តដើរទៅមុខរហូតបង្កើតបាន «បណ្តាញក្រុមជំនុំ » និង ចាត់ គ្រីស្តទូតទៅកាន់ជាតិសាសន៍ និងក្រុមមនុស្សដែលមានវប្បធម៌ផ្សេងៗទៀត ។

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ ការអធិស្ឋានជាប្រចាំរបស់ពួកអ្នកជឿទាំងអស់គ្នា ។
- ☐ ការបន្តផ្សាយដំណឹងល្អប្រាប់ដល់បងប្អូន មិត្តភក្តិ និងអ្នកធ្លាប់ស្គាល់ ។
- ☐ ការបង្រៀន និងការប្រព្រឹត្តតាមសេចក្តីបង្គាប់សំខាន់ៗរបស់ព្រះអម្ចាស់ ។
- ☐ គុណសម្បត្តិ និងខ្លឹមសារខាងព្រលឹងវិញ្ញាណរបស់ការប្រជុំថ្វាយបង្គំ ។
- ☐ របៀបរៀបចំរបស់ក្រុមជំនុំ ។
- ☐ សេចក្តីស្រឡាញ់ និងការប្រកបគ្នារបស់ក្រុមជំនុំ ។
- ☐ ការសួរសុខទុក្ខ និងការថែរក្សា (ការឃ្វាល)ក្រុមជំនុំ ។
- ☐ កិរិតនៃការប្តេជ្ញាចិត្ត និងការចាត់ចែងថវិកា/ការថ្វាយដង្វាយរបស់ក្រុមជំនុំ ។
- ☐ មនុស្សដែលអាចក្លាយជានិស្សិតគ្រូគង្វាលថ្មី ។
- ☐ ការយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយដំណឹងល្អដល់មនុស្សទូទាំងពិភពលោក ។
- ☐ សកម្មភាពទាំងអស់របស់កិរិត ទី ១ ។

ការសិក្សា (សំរាប់ជ្រើសរើស)

កូនស្សៀរភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល :

☐ ១០ « ការរីកចំរើនឡើងខាងចរិតលក្ខណៈរបស់គ្រីស្តជន »

☐ ២៨ « ការពិនិត្យមើលសកម្មភាពកិរិតទីមួយសាឡើងវិញ »

ការអានបន្ថែម :

ស-១៩ រៀបចំអោយមានការអធិស្ឋានក្នុងក្រុមជំនុំ

កិច្ចការដែលត្រូវអនុវត្ត (សំរាប់ជ្រើសរើស)

- ☐ បង្រៀនពួកអ្នកជឿអោយចេះពឹងផ្អែកលើព្រះជាម្ចាស់ តាមរយៈការអធិស្ឋាន ។
- ☐ ធ្វើអោយមានការអធិស្ឋាននៅគ្រប់ផ្នែកនៃជីវិតរបស់ក្រុមជំនុំ ។
- ☐ បង្កើតក្រុមអធិស្ឋាន ដែលជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីអធិស្ឋានសំរាប់ការងារ ។
- ☐ ពង្រឹងការអធិស្ឋានទូលអង្វរនៅក្នុងការប្រជុំថ្វាយបង្គំរបស់ក្រុមជំនុំ ។
- ☐ រៀបចំឱ្យមានការអធិស្ឋានពិសេស ដែលមនុស្សទូលអង្វរជាប្រចាំ សំរាប់ការងារក្នុងក្រុមជំនុំ ។
- ☐ បង្កើតបណ្តាញអ្នកអធិស្ឋានចាំយាម សំរាប់រយៈពេលពេញមួយថ្ងៃ ឬ ពេញមួយយប់ ។
- ☐ បង្រៀនពួកសមាជិកអោយចេះតមអាហារ ដើម្បីអធិស្ឋានពិសេសអំពីការរីកសាយព្រះរាជ្យ ព្រះជាម្ចាស់ ។

ការសិក្សា (សំរាប់ជ្រើសរើស)

ការអានព្រះគម្ពីរ :

- ☐ សិក្សាក្នុង ដានីអែលទាំងមូល : គំរូពីជំនឿរបស់លោកដានីអែល និងមិត្តសំឡាញ់របស់គាត់ ។
